PORTLAND PUBLIC SCHOOLS
prepared & empowered

មីនា ២០២០

គ្រួសារ បុគ្គលិក សហគមន៍ សាលាសាធារណៈភទឡែន ជាទីមេត្រី សូមជ្រាប។

ក្នុងពេលថ្មីៗកន្លងមកនេះ ខ្ញុំបានសរសេរសំបុត្រជម្រាបលោកអ្នកអំពីវិធី ដែលយើងគ្រប់រូបអាចធ្វើ ដើម្បីការពារការរាលដាលនៃមេរោគ ខូរ៉ូណាវ៉ាយរ៉ាស់-១៩ បើសិនជាវាកើតមានឡើងក្នុងសហគមន៍របស់យើង។ ពេលនេះខ្ញុំសរសេរមកទៀត សុំជំនួយគ្រប់គ្នា ទប់ទល់និងបញ្ហាមួយទៀត ដែលពាក់ព័ន្ធរឿងខូរ៉ូណាវ៉ាយរ៉ាស់-១៩នេះដែរ៖ ការសន្មត់ រំខាន របស់សិស្ស បុគ្គលិក សមាជិកសហគមន៍ ធ្វើឡើងចំពោះសិស្សមានខ្សែស្រឡាយអាមេរិកាំងដើមកំណើតចិននិងអាស៊ី។

វាមានការកាន់តែរីករាលដាលច្រើនឡើងៗទូទាំងប្រទេសអំពីរវាយកាណ៍គ្មានហេតុផលនិងជាអំពើខុសឆ្គងមួយ ដោយយោងទៅតាមក្រសួងអបរំនិងសិក្សាសហរដ្ឋ ផ្នែកការិយាល័យសិទ្ធិមនុស្ស *(OCR*។. *"*របាយការណ៍ទាំងនេះគឺជាសេចក្ដីអំពលនិងការប៉ះពាល់សតិអារម្មណ៍ដ៏ធំមួយ*"*។ នេះបើយោលទៅតាមលិខិតមួយច្បាប់ ផ្ញើទៅជូនបុគ្គលិកគ្រូបង្រៀន ក្នុងពេលថ្មីៗនេះ។

ខូរ៉ូណាវ៉ាយរ៉ាស់-១៩ បានត្រូវរកឃើញក្នុងពេលវារាតត្បាតទីក្រុងវូហាន ប្រទេសចិន។ ប៉ុន្តែ មកទល់ពេលនេះ ត្រូវគេរកឃើញមានក្នុងប្រទេស រួមទាំងសហរដ្ឋផងដែរ។ ក្នុងពេលខ្ញុំកំពុងសរសេរមកនេះ យើងមិនមានរបាយការណ៍អំពីខូរ៉ូណាវ៉ាយរ៉ាស់-១៩កើតក្នុងរដ្ឋម៉ែនទេ ហើយថាវានឹងកើតមាននោះគឺសឹងថាគ្មានទេ។ គិលានុបដ្ឋាយិកាសាលាយើងនិងថ្នាក់ដឹកនាំកំពុងតែសហការគ្នាយ៉ាងជិតស្និទ្ធជាមួយក្រសួងសុខុមាលភាព មជ្ឈមណ្ឌលទប់ស្កាត់ជម្ងឺរដ្ឋម៉ែន *(Maine CDC)*និងក្រសួងសិក្សានិងអប់រំរដ្ឋម៉ែន ដើម្បីជម្រាបជូនដំណឹងទាន់ហេតុការណ៍កើតមាន។

លិខិត *OCR* បញ្ជាក់ថា *"*ក្នុងបរិយាកាសដ៏គួរឱ្យភ័យខ្លាចមួយនេះ *…*មនុស្សមួយចំនួនអាចបង្វែងដានទម្លាក់កំហុសទៅលើពូជសាសន៍ ឬការសន្មត់លើពួកអនិកជននានា*"*។ ការគម្រាមសម្លុត ការរំខាន ការប្រកាន់ពូជសាសន៍នេះ អាចកើតមានស្ទើរគ្រប់រូបភាព មានតាំងពីការញោះញង់ពាក្យសសម្ដី រហូតដល់កើតអំពើហឹង្សា បណ្ដាលមកពីពូជសាសន៍ ខ្សែស្រឡាយឬក៏ការភ័ន្តច្រឡំអំពីទំនៀមទម្លាប់នានាផងគេ*"*

ក្នុងនាមសង្កាត់សាលាសាធារណៈភទឡែន ដែលមានសិស្សចម្រុះសញ្ជាតិច្រើនជាងគេក្នុងរដ្ឋម៉ែន យើងមានបិតិសោមនស្សច្រើនណាស់ចំពោះសិស្សចម្រុះសញ្ជាតិ ហើយយើងចាត់ទុកវាជាធនធានមួយ សម្រាប់ការសិក្សារបស់សិស្ស។ យើងមិនអនុញ្ញាតជាដាច់ខាត អំពើអុកឡុករំខាន ការសម្លុតឬប្រកាន់ពូជសាន៍ទៅលើសិស្សទាំងឡាយរបស់យើងនិងបុគ្គលិក ទោះជាក្នុងការទេសៈណាទាំងអស់។ មិនតែប៉ុណ្ណោះសោត សាលាយើងខ្ញុំ តែងតែធ្វើការងារធានាថា ជាទីកន្លែងមួយជាវិជ្ជមាន សម្រាប់សិស្សយើងគ្រប់រូបសិក្សារៀនសូត្រ។

PORTLAND PUBLIC SCHOOLS
prepared & empowered

ម្យ៉ាងទៀត យើងខ្ញុំប្រឹងប្រែងរក្សាសុខភាពមនុស្សគ្រប់រូបក្នុងសហគមន៍សាលាសាធារណៈរបស់យើង។ ការសន្មត់គ្មាន់ហេតុផលលើបុគ្គលណាមួយ ការសម្អុតគម្រាម និងការរុកគួនអ្នកដទៃ វាអាចបង្កើតការភ័ន្តច្រឡំនិងការភ័យខ្លាច។ នោះជាទង្វើមួយមិនប្រកបទៅដោយសុខភាព សម្រាប់យើងរាល់គ្នាឡើយ។

សូមកុំញញើតទាក់ទងគិលានុបដ្ឋាយិកាសាលារៀន បើមានសំណួរឬការព្រួយបារម្ភអំពី ខូវិដ-១៩ និងធ្វើរបាយការណ៍ នៃការរំខានឬប្រកាន់ពូជសាសន៍ ទៅថ្នាក់ដឹកនាំទាំងឡាយរបស់សាលារៀន។

ខ្ញុំនឹងបន្តធ្វើរបាយការណ៍ថ្មីៗ ទាក់ទងនិង វ៉ាយរ៉ាស់នេះ ដែលកើតមានក្នុងស្រុក ជូនលោកអ្នកជ្រាប ហើយនាពេលនេះ សូមសម្រាកនៅផ្ទះ បើអ្នកមិនស្រួលខ្លួន បិទបាំងការក្អកនិងក្រដាស់ លាងដៃឱ្យបានទៀងទាត់ ហើយសូមមេត្តាជួយគ្នាទៅវិញទៅមក។ ដំណឹងពិស្តារ អំពីខូវិដ-១៩ អាចអានបាននៅ: [https://www.cdc.gov/coronavirus](https://www.cdc.gov/coronavirus)

បណ្ឌិត ហាវ៉ា បូថាណា ឧត្តមនាយកសាលា

P424- KHM COVID-19 Letter